សុន្ទរកថារបស់**លោក កាម៉ូស៊ីដា ណាអ៊ូអាគី**

ទីប្រឹក្សា ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ថ្លែងក្នុងពិធីប្រគល់រទេះរុញសម្រាប់កុមារពិការនៅការិយាល័យ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានីភ្នំពេញ

**ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥**

- សូមគោរព **ឯកឧត្តម វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- សូមគោរព **ឯកឧត្តម ជិន ម៉ាលីន** អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌
- សូមគោរព **ឯកឧត្តម ឯម ច័ន្ទមករា** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ
- សូមគោរព **លោក តូម៉ូយូគី កាតាណូ** ប្រធានក្រុមអ្នកស្ម័គ្រចិត្តដើម្បីបញ្ជូនរទេះរុញសម្រាប់កុមារពិការពីប្រទេសជប៉ុនទៅបរទេស
- សូមគោរព ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី!

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយដែលបានចូលរួមក្នុងពិធីប្រគល់នេះ ជាមួយនឹងវត្តមានដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តម វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីប្រគល់រទេះរុញសម្រាប់កុមារពិការចំនួន១៦០ ដល់មជ្ឈមណ្ឌលស្តារនីតិសម្បទាចំនួន១០ និងមជ្ឈមណ្ឌលមួយចំនួនទៀតនៅក្នុងប្រទេសកម្ពុជា។

ការបរិច្ចាគនូវរទេះរុញសម្រាប់កុមារពិការទាំងអស់នេះ ត្រូវបានធ្វើឡើងតាមរយៈ "ក្រុមអ្នកស្ម័គ្រចិត្តដើម្បីបញ្ជូនរទេះរុញសម្រាប់កុមារពិការទៅបរទេស" ដែលហៅកាត់ថា NPOជប៉ុន ដោយមានកិច្ចសហប្រត្តិបត្តិការជាមួយនឹងរដ្ឋាភិបាលជប៉ុន។

ក្នុងរយៈពេលពីរទស្សវត្ស៍មកនេះ ប្រទេសកម្ពុជាមានការអភិវឌ្ឍយ៉ាងឆាប់រហ័សគួរអោយកត់សំគាល់ ដែលធ្វើអោយស្ថានភាពរស់នៅរបស់ប្រជាជនកម្ពុជាជាទូទៅមានលក្ខណៈប្រសើរឡើង។ យ៉ាងណាមិញ ប្រទេសកម្ពុជានៅតែមានបញ្ហាប្រឈមជាច្រើនផងដែរ។ ជាក់ស្តែង ការរស់នៅរបស់កុមារពិការនៅតែមានការលំបាកគួរអោយកត់សំគាល់ ដោយសារតែកង្វះនូវការឧបត្ថម្ភគាំទ្រអោយបានគ្រប់គ្រាន់។ កុមារពិការទាំងនេះ បានរងគ្រោះដោយសារការផ្ទុះគ្រាប់មីនដែលកប់ក្នុងដី ឬរងផលប៉ះពាល់ដោយពិការចលករខួរក្បាល ដែលធ្វើអោយពួកគេ មិនបានទទួលនូវសេវាកម្មថែទាំពីមជ្ឈមណ្ឌលស្តារនីតិសម្បទា ឬមន្ទីរពេទ្យអោយបានត្រឹមត្រូវ។កត្តាទាំងអស់នេះហើយដែលធ្វើអោយពួកគេបាត់បង់ឱកាសចូលសាលារៀន និងចូលរួមក្នុងសកម្មភាពសង្គមនានា។

នៅក្នុងបរិបទនេះ យើងសូមសម្តែងនូវការកោតសរសើរដល់ "ក្រុមអ្នកស្ម័គ្រចិត្តដើម្បីបញ្ជូនរទេះរុញសម្រាប់កុមារពិការទៅបរទេស" ដែលហៅកាត់ថាNPOជប៉ុន ដែលបានបរិច្ចាគរទេះរុញសម្រាប់កុមារពិការចំនួន៣២០ ដល់មជ្ឈមណ្ឌលស្តារនីតិសម្បទានៅទូទាំងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ២០១០មក ដើម្បីអោយកុមារពិការមានមធ្យោបាយគ្រប់គ្រាន់អាចធ្វើដំណើរទៅកាន់មជ្ឈមណ្ឌលស្តារនីតិសម្បទា និងមន្ទីរពេទ្យនានាបាន។ យើងក៏សូមសម្តែងនូវការដឹងគុណផងដែរ ដល់ក្រុមប្រឹក្សាសកម្មភាពជនពិការ និងសមាគមអតីតនិស្សិតអង្គការJICAនៅកម្ពុជា ដែលបានជួយដល់ក្រុមអ្នកស្ម័គ្រចិត្តក្នុងការអនុវត្តគម្រោងនេះ។

តាមរយៈគម្រោងនេះ កុមារពិការជាច្រើនអាចចូលរៀន និងចូលរួមក្នុងសកម្មភាពសង្គមផ្សេងៗបាន ដោយការប្រើប្រាស់នូវរទេះរុញជំនួយឧបត្ថម្ភទាំងអស់នេះ។ ខ្ញុំមានសេចក្តីរីករាយដែលបានប្រគល់ជូនទេះរុញសម្រាប់កុមារពិការចំនួន១៦០នាពេលនេះ ដែលនឹងបង្កើនចំនួនរទេះរុញសម្រាប់កុមារពិការទាំងនេះបន្ថែមទៀត ដើម្បីជួយពង្រីកការយល់ដឹងរបស់ពួកគេអោយកាន់តែប្រសើរឡើង។ ខ្ញុំជឿជាក់ថា គម្រោងនេះ នឹងលើកកម្ពស់ការយល់ដឹងអំពីតម្រូវការពិសេសរបស់កុមារពិការក្នុងចំណោមប្រជាជនកម្ពុជាទាំងអស់ ដើម្បីរួមចំណែកក្នុងការបង្កើតបរិយាបន្នបរិស្ថានមួយសម្រាប់កុមារពិការ។

តាងនាមអោយរដ្ឋាភិបាលជប៉ុន ខ្ញុំសូមសម្តែងនូវការកោតសរសើរដោយស្មោះសរជាថ្មីម្តងទៀត ចំពោះលោក-អ្នកទាំងអស់ ដែលបានខិតខំប្រឹងប្រែង សម្រាប់អនាគតដ៏ល្អប្រសើររបស់កុមារពិការ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា រទេះរុញសម្រាប់កុមារពិការទាំងអស់នេះ នឹងត្រូវបានប្រើប្រាស់យ៉ាងមានប្រសិទ្ធភាព និងជួយថែរក្សារទេះរុញទាំងនេះអោយបានត្រឹមត្រូវល្អ ដើម្បីទុកជានិមិត្តរូបនៃទំនាក់ទំនងមិត្តភាពរវាងប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជា។

**សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!**